

## តើជា អវសាន នៃ វប្បធម៌សន្ទនា ?

ពហិការ របស់ គណសង្គ្រោះជាតិ មិនព្រមចូលប្រជុំ អនុម័ត សេចក្តីព្រាងច្បាប់ ស្តីអំពី សមាគម និង អង្គការមិនមែន រដ្ឋាភិបាល ដែល មតិជាតិ និង មតិអន្តរជាតិ ធ្វើការ រិះគន់ ថាជា ច្បាប់ រឹតត្បិត សេរីភាព នៃការបញ្ចេញមតិ និង សិទ្ធិប្រជាពលរដ្ឋ នាំចោទ ជាសំនួរមួយថា តើជា ដំណាច់ នៃវប្បធម៌ សន្ទនា រវាង គណបក្ស ប្រជាជនកម្ពុជា ជាមួយនឹង សង្គ្រោះជាតិ ?

សំនួរ នេះ ពិបាកនឹងឆ្លើយ ព្រោះ វប្បធម៌ សន្ទនា ជា ការបង្កើត មួយ មានតែឈ្មោះ តែគ្មាន រូបរាង និង គំនិត ច្បាស់លាស់ ហើយតាំងពី លោក សម-រង្សី និង ហ៊ុន-សែន លើកវាយកមកនិយាយ គេមិនដែលឃើញ មានអ្វីមួយជាក់ស្តែង ជា វិជ្ជមាន សំរាប់ប្រជាជាតិ ក្រៅពី លោកទាំងពីរ បណ្តើរគ្នា ទៅទីហ្នេះ ទៅទីហ្នោះ ទៅបាយទឹក នៅ ភោជនីយដ្ឋាន សើចសប្បាយ ដូចជាមានសេចក្តីសុខនឹងគ្នាណាស់។ ដូច្នេះ បើយើងលើកយក វប្បធម៌នេះមក គិតពិចារណា វាឃើញ មានលក្ខណៈ ជា រឿងផ្តាល់ខ្លួន របស់ លោកទាំងពីរនេះសុទ្ធសាធ ទោះបី គាត់ ខំនិយាយថា សេចក្តីសុខ របស់ពួកគាត់ គឺជា សេចក្តីរបស់ប្រជាពលរដ្ឋ ក៏ដោយ តែពួកគាត់ ភ្លេចគិតថា ពួកគាត់មានសេចក្តីសុខ លើគំនរទ្រព្យ រីឯ ប្រជាពលរដ្ឋ វិញ គាត់ មាន សេចក្តីសុខ នៅក្នុងគំនរទុក្ខ ដែល លោក ហ៊ុន-សែន ហៅថា សន្តិភាព តែ សន្តិភាព នេះ វាជា សន្តិភាព ទាញបានកម្រៃ (paix lucrative) សំរាប់តែ បក្សពួក និង គ្រួសារ របស់ ពួកគាត់ តែប៉ុណ្ណោះ។

នៅក្នុង វប្បធម៌ សន្ទនា នេះ លោក សម-រង្សី គាត់ចង់ ដើរតួ ជា «មនុស្ស មាន ឥទ្ធិពល» (homme d’influence) ទៅលើ ហ៊ុន-សែន និង ជា ទូត នៃរូបភាព សន្តិភាព និង ស្ថិរភាព (Ambassadeur de la paix et de la stabilité) របស់ កម្ពុជា លើឆាក អន្តរជាតិ អោយ ហ៊ុន-សែន។ ក្នុងតួ នេះ គាត់ សន្យានឹង ហ៊ុន-សែន ថា គាត់ លែងចង់បាន អំណាចហើយ ព្រោះគាត់ ចាស់ហើយ តែចង់ជួយស្តារ របប ហ៊ុន-សែន ឲមាន សោភ័នភាព លើឆាកអន្តរជាតិ និង ជាគំរូ នៃឯកភាពជាតិ ដល់យុវជន។ គាត់ចង់ធ្វើជា សន្តជនដូចលោក Ghandi បំរើប្រយោជន៍ ហ៊ុន-សែន ព្រោះគាត់ទុក ប្រយោជន៍នេះ ជាការរក្សាសន្តិភាព។

រីឯ លោក ហ៊ុន-សែន វិញ គាត់ចង់ ដើរតួ ជា «មនុស្ស សន្តិភាព» តែដូចធ្លាប់ជំរាបខាងលើរួចហើយ ថា សន្តិភាព លោក ហ៊ុន-សែន ជាសន្តិភាព អោយយួន មករស់នៅក្នុងទឹកដីខ្មែរ គ្មានខ្លាច ញញើត ច្បាប់ខ្មែរបន្តិច សោះឡើយ ហើយ អោយ យៀកណាម បំពាន បូរភាពទឹកដី និង ឯករាជ្យជាតិ នៃប្រទេស ខ្មែរគ្មានឈប់ឈរ។

ដោយ ឧប សៅ សង្ហា
២០ កក្កដា ២០១៥

ក្នុង វប្បធម៌ សន្ទនា នេះ វាមាន នាមកត្តា រួមមួយ នៅក្នុងតួ របស់លោក ទាំងពីរហ្មេះ គឺ «ថែរក្សាអំណាច របស់ ខ្លួនផ្ទាល់»៖ លោក សម-រង្ស៊ី គឺ ថែរក្សា អំណាច នៅក្នុង គណបក្សសង្គ្រោះជាតិ រីឯ លោក ហ៊ុន-សែន វិញ នៅ ក្នុង គណបក្សប្រជាជន។ ដូច្នេះ ការផ្សះផ្សាគ្នា រវាង លោក ទាំងពីរ គឺជាការចាំបាច់មួយ សំរាប់ ពួកគាត់ បិទមាត់ គ្រប់រូបភាព នៃ វិវាទកម្ម ដែលអាចកើតមានឡើង នៅក្នុងផ្ទៃក្នុង នៃគណបក្សរៀងៗខ្លួន ព្រោះ ក្នុងករណី លោក សម-រង្ស៊ី បរាជ័យ ជាក់ស្តែង នៃការដឹកនាំបាតុកម្មមហាជនប្រឆាំងនឹង ហ៊ុន-សែន នាំឲគាត់បាត់បង់ នូវតម្លៃរបស់គាត់ ជា មេដឹកនាំ ជាធម្មជាតិ (leader naturel)។ ឯចំណែក លោក ហ៊ុន-សែន ការផ្ទុះ បាតុកម្ម មហាជន នាំឲគ្នាគាត់ចោទជាសំណួរ ថា តើគាត់ នៅមាន ធម្មានុរូប បន្តដឹងនាំ គណបក្ស និង រដ្ឋាភិបាល បានទៀតដែរ ឬទេ ?

## ប្រយោជន៍ លោក សម-រង្ស៊ី

ដូច្នេះ ការរត់ទៅពឹង លោក ហ៊ុន-សែន តាម វប្បធម៌សន្ទនា ជា ការចាំបាច់ មួយ សំរាប់ បង្ហាញដល់តែ ពួកអ្នក ជំទាស់ នឹងគំនិតគាត់ ថា គាត់ នៅមាន ជីវិតនយោបាយ ដោយសារគាត់ មានទំនាក់ទំនង ជាគុណភាព ជាមួយ ហ៊ុន-សែន ដែលជា មនុស្សខ្លាំង នៅកម្ពុជា ព្រោះនៅក្នុងជួរ អ្នកដឹកនាំ នៃគណបក្សសង្គ្រោះជាតិ មាន មនុស្សមួយក្រុម ទុក ហ៊ុនសែន ជា មជ្ឈមណ្ឌល ចែកកម្រៃ ហើយ មនុស្សមួយក្រុមទៀត ទុកហ៊ុន-សែន ជា យោមរាជ។ ដូច្នេះ មាន ជម្លោះ ជាមួយ សម-រង្ស៊ី ដែលជាក្លើនឹង ហ៊ុន-សែន វា អាចបាត់ប្រយោជន៍ ចំពោះ ពួកមនុស្សទី១ ហៅថា អ្នកឃ្លាន កម្រៃ រីឯ ពួកមនុស្សទី២ ហៅថា អ្នកខ្លាច វិញ គឺ វាអាចមានគ្រោះថ្នាក់ដល់ជីវិត។ តែមានពួកមនុស្សទី៣ ហៅថា អ្នកហ៊ាន យកច្បាប់ជាគោល ហ៊ានប្រឆាំង រាល់អំពើណា ដែលផ្ទុយនឹងច្បាប់ ផ្ទុយនឹង លទ្ធិប្រជាធិបតេយ្យ និងអ្វីៗគ្រប់បែបយ៉ាង ដែលនាំឲមាន គ្រោះថ្នាក់ដល់ប្រជាជាតិ។ ក្រុមទី៣ នេះឯង អាច រក្សាគោលដៅទ្រឹស្តី របស់គណបក្សសង្គ្រោះជាតិបានខ្លះដែលនាំរំខាន ដល់ វប្បធម៌សន្ទនា របស់ លោក សម-រង្ស៊ី ដែលជា វប្បធម៌ ទុកប្រយោជន៍ផ្ទាល់ខ្លួន លើច្បាប់។ ការយល់ របស់ លោក សម-រង្ស៊ី ថា វប្បធម៌សន្ទនា វាអាច រក្សា សន្តិភាព ដែលជាកត្តា អាចឲមានការប្តូរអំណាចបាន តាមផ្លូវសន្តិវិធី ជា គំនិតមួយ គ្មានទំនង ទាល់តែសោះ ព្រោះវាគ្មាន សន្តិភាព ណាមួយ គ្មានច្បាប់ជាមូលដ្ឋាន នោះឡើយ។ សន្តិភាព បែបនេះ គេហៅថា «អំណាចផ្តាច់ការ» ដូច ប្រទេសកូរ៉េខាងជើង, ប្រទេសយៀកណាម ជាឧទាហរណ៍។ សួរថា តើ លោក សម-រង្ស៊ី គាត់ចង់បាន សន្តិភាព បែបនេះ ឬ ? បើគាត់ ចង់បាន គឺ ប្រាកដ ជាគាត់ទុក កិច្ចព្រមព្រៀងសន្តិភាព២៣តុលា ១៩៩១ ជា មោឃៈ ហើយ ធ្វើឲ ដំណើរ នៃលទ្ធិប្រជាធិបតេយ្យ នឹងដើរត្រឡប់ថយក្រោយវិញ ទៅរក ថ្ងៃទី៧មករាឆ្នាំ ១៩៧៩ ជាមិនខាន។ រឿងលោក សម-រង្ស៊ី និង កឹម សុខា

ដោយ ឧប សៅ សង្ហា
២០ កក្កដា ២០១៥

អស់មធ្យោបាយ ធ្វើសកម្មភាពនយោបាយ ប្រឆាំងនឹង របបផ្តាច់ការ ដូចគាត់ធ្លាប់ប្រកាស ជាឧឡារិក ជារឿងផ្ទាល់ខ្លួនរបស់លោក ទាំងពីរ តែនាំគ្នាប្តូរទិសនយោបាយទៅរួមធ្វើ សហប្រតិបត្តិការ ជាមួយ លោក ហ៊ុន-សែន ក្នុង វប្បធម៌សន្ទនា និយាយខ្សឹបៗក្នុងភោជនីយដ្ឋាន ជាអំពើមួយក្បត់ ម្ចាស់ឆ្នោត និង ក្បត់ឧត្តមគតិខ្លួនឯង។ ពួកគាត់នាំគ្នាចូល រដ្ឋសភា របស់ ឈាង វុន គឺទុកជា ទង្វើរឡេះរឡោះ ដូចកូនក្មេង រួចទៅហើយ តែបើបានជាចូលហើយនាំគ្នាធ្វើខ្លួន ឲទៅជាអ្នក មានមាយាទជាអ្នកប្រជាធិបតេយ្យនិយម ធ្វើសកម្មភាព ជាអ្នកប្រឆាំងត្រឹមត្រូវតាមច្បាប់ប្រហែលអាចទុកបានជា ហ្វ្រាំងមួយ ទប់ល្បឿន នៃអំណាចផ្តាច់ការ ដើម្បីរកប្រយោជន៍ឲជាតិ តែបែរ ជានាំគ្នា ប្រើ វប្បធម៌សន្ទនា ខ្សឹបៗក្នុងភោជនីយដ្ឋាន ដែលជាល្បឿនបំថែម រុញរបបផ្តាច់ការឲកាន់តែមាន ប្រសិទ្ធិភាព លឿនដាច់ ល្បឿន នៃលទ្ធិប្រជាធិបតេយ្យ ទៅវិញ។ សួរថាតើ សម-រង្ស៊ី ជាមនុស្សឆ្លាត ហើយ ហ៊ុន-សែន ជាមនុស្សល្ងីល្ងើ ឃ្លាតខ្មី អនុវត្ត វប្បធម៌សន្ទនា ដើម្បី ប្រគល់អំណាច ឲ គណបក្សសង្គ្រោះជាតិ ? ការនេះ ជា សុបិនមួយរបស់ សម-រង្ស៊ី តែប៉ុណ្ណោះ។

## ប្រយោជន៍ លោក ហ៊ុន-សែន

ប្រយោជន៍ ហ៊ុន-សែន ទាញយកពី វប្បធម៌សន្ទនា ខ្សឹបៗក្នុងភោជនីយដ្ឋាន មានតែមួយគត់ គឺ រក្សាអំណាចយួន នៅស្រុកខ្មែរ ព្រោះនៅក្នុងអំណាចនោះ ខ្លួនបានទទួលជាកម្រៃ ធ្វើជាសេដ្ឋី និង ជា អ្នកអាន់ជ្រី លើខ្មែរគ្នាឯង ដែល អាចឲយួន រក្សាការពារខ្លួន ឲរស់ជាអ្នកអាន់ជ្រីបន្តទៅមុខទៀត។ ហ៊ុន-សែន ត្រូវការ សម-រង្ស៊ី ដើម្បី បិទផ្លូវ ដល់ អ្នកទំនាស់នឹងគំនិត របស់ខ្លួន កុំអោយទុក សម-រង្ស៊ី ជា អនិយ័ត (alternative) នៃអំណាច បាន ព្រោះបើអ្នកទាំងនោះ មានជំនឿទៅលើ លោក សម-រង្ស៊ី គឺ វានៅតែនៅក្រោម ហ៊ុន-សែន ដដែល ព្រោះ សម-រង្ស៊ី គ្រាន់តែជា ប្រតិរូប ហ៊ុន-សែន ក្នុងខ្នាតតូចតែប៉ុណ្ណោះ។ យួន និង ហ៊ុន-សែន ដឹងច្បាស់ណាស់ថា សម-រង្ស៊ី ជា ពស់ អស់ពិសហើយ តែនៅមានប្រយោជន៍ សំរាប់ ធ្វើទស្សនីយភាព នៅពេលបោះឆ្នោត ក្នុងឋានៈ ជា ឃោសនិក ដើម្បីបង្ហាញ សហគមអន្តរជាតិ ថាមាន គណបក្សប្រឆាំង ចូលរួម ការបោះឆ្នោត។ រឿងឈ្នះចាញ់ឆ្នោត ចំពោះ ហ៊ុន-សែន គាត់ លែងឲមានកើតជា បញ្ហា ទៀតហើយ គឺ គាត់ នឹងប្រើមធ្យោបាយ គ្រប់បែបយ៉ាង ដើម្បីយកឈ្នះឆ្នោត ជាដាច់ខាត។ គណបក្សប្រជាជនកម្ពុជា មានអ្នកគាំទ្រ ដើម្បី ប្តូរយកប្រយោជន៍ (clientélisme) សំរាប់ បោះឆ្នោតអោយ គឺ យួនមានសញ្ជាតិជាខ្មែរប្រមាណជាង ១លាននាក់ ក្នុងចំណោម យួនមករស់នៅស្រុកខ្មែរ មានចំនួនប្រមាណ ៥ លាន នាក់។ ផ្នែក នៃពួកអ្នកបោះឆ្នោតនេះ ជាគ្រឹះ នៃនយោបាយ របស់ គណបក្សប្រជាជនកម្ពុជា។ ដូច្នេះហ៊ុន-សែន មិនពិបាកនឹង លួចសន្លឹកឆ្នោតទេ ដើម្បីយក អាសនៈ ៥០+

ដោយ ឧប សៅ សង្ហា
២០ កក្កដា ២០១៥

១ នៅក្នុង រដ្ឋសភា ព្រោះខ្លួនមានសម្លេងឆ្នោតគ្រាន់បើដែរ។ លើសពីនេះទៅទៀត ទោះបីចាញ់ឬឈ្នះបើ គ.ជ.ប. គេប្រកាសតាមអធិបញ្ញា (ordre formel) ពីហ៊ុនសែន[1] ថា គណបក្សប្រជាជន ជាអ្នកឈ្នះ តើមាន នរណា អាចប្រកែកបានបើ ហ៊ុន-សែន គាត់ តែងតែនិយាយថា បើគាត់ចាញ់គឺមានសង្គ្រាម បានសេចក្ដីថា គាត់មិនព្រម ចុះចេញ ពីអំណាច ជាដាច់ខាត។ ដូច្នេះ គឺវាគ្មានអ្វីខុសពី អាណត្តិ ទី៥ គឺ គ្រប់គណបក្ស ដែល គ.ជ.ប. ទុកជាអ្នកចាញ់ឆ្នោត នាំគ្នាដើរចូលរដ្ឋសភា ហើយ អនុវត្ត វប្បធម៌សន្ទនា ខ្សឹបៗ ក្នុងភោជនីយដ្ឋាន បន្តទៅទៀត ដើម្បី ស្រួលរស់ចិញ្ចឹមជីវិតដូច លោក សម-រង្ស៊ី គាត់ ធ្លាប់ថ្លែង ជាសាធារណៈ។ ការសុំរស់ បានសុខនេះ ជា ឃ្លាដែលគេ ទន្ទេញមិនឈប់ (leitmotiv) ដ៏សំខាន់មួយ របស់ វប្បធម៌សន្ទនាខ្សឹបៗក្នុងភោជនីយដ្ឋាន របស់ លោក សម-រង្ស៊ី។

លោក ហ៊ុន-សែន ចង់រក្សាអំណាច រីឯ លោក សម-រង្ស៊ី ចង់បានសុខ ដូច្នេះ កត្តា ទាំងពីរនេះ វា ជាផ្លូវស្របគ្នា ទៅកាន់គោលដៅតែមួយ គឺប្រយោជន៍យួន នោះឯង។ គណបក្ស លោក សួន សេរី រដ្ឋា ក្ដី លោក ម៉ម សាណង់ដូរ ក្ដីទោះបីលោកទាំងពី មាន សន្ដានចិត្ត ល្អ ក៏ដោយ តែ វានៅ ក្នុងទ្រុងយួន ដ៏ដែល បើលោកទាំងពីរ នាំគ្នាចូលរួមបោះឆ្នោត ក្នុងល្បិចយួន ដែលមានតាំងពី អាណត្តិ ទី២ មកម្លេះ។

ចំពោះ លោក ហ៊ុន-សែន គាត់មានតែចំណេញ ក្នុង វប្បធម៌សន្ទនា ខ្សឹបៗក្នុងភោជនីយដ្ឋាន ព្រោះវាជាការសុំ ពី លោក សម-រង្ស៊ី ហេតុនេះឯង កាលណាគាត់មើលឃើញអ្វីមួយ ដែលអាចនាំឲខាតប្រយោជន៍គាត់ គាត់តែងតែព្រមាន បញ្ចប់វា ជានិច្ច ហើយរាល់លើក គឺ លោក សម-រង្ស៊ី ត្រូវ ស្នើរសុំជាថ្មី ឲរក្សា វា ជានិច្ច។ យូរៗទៅ វាហាក់បីឃើញថា លោក សម-រង្ស៊ី គាត់ ក្លាយជា យាចក គិតតែពីសុំសុខ តែប៉ុណ្ណោះ។ រូបភាព លោក សម-រង្ស៊ី ជា យាចក នេះឯង ដែលនាំឲ គាត់ ក្លាយ ជាមនុស្សខ្សោយបំផុតចំពោះមុខ លោក ហ៊ុន-សែន។

**ករណី លោក កិម-សុខា**

លោក កិម-សុខា គាត់យក យុទ្ធសាស្ត្រ «សម្ងំធ្វើស្លាប់» ក្នុង វប្បធម៌សន្ទនា ដើម្បីគេចវេះ តុលាការ ហ៊ុនសែន រហូតដល់ពេល បោះឆ្នោត ទើបគាត់ងើបពី ក្ដារមឈូស

[1] ត្រូវចងចាំថា ក្នុងឆ្នាំ ២០១៣, អ្នកដែលប្រកាស ថាគណបក្សប្រជាជន មានជ័យជំនះ គឺ រដ្ឋមន្ត្រីក្រសួងព័ត៌មាន មុន គ.ជ.ប.។ ហ្នេះហើយ ជា អធិបញ្ញា របស់ ហ៊ុន-សែន ទៅកាន់ គ.ជ.ប.។

ព្រោះគាត់ យល់ឃើញថា ហ៊ុន-សែន ត្រូវការគាត់ ជា ឃោសនិក នៃការបោះឆ្នោតដូច ត្រូវការ សម-រង្ស៊ី ដែរ។ តែលោក កឹម-សុខា ភ្លេច បុរាណភាសិត មួយថា «កុក វាតែង ភ្លេចផុច តែផុច វាមិនដែលភ្លេចកុក នោះឡើយ»។ បើពិតជា លោក កឹម-សុខា ប្រើយុទ្ធសាស្ត្រនេះមែន គឺជាការភាន់ច្រឡំមួយសុទ្ធសាធ ព្រោះ តុលាការ ហ៊ុន-សែន វាមិនភ្លេច ជាដាច់ខាត កឹម-សុខា នៅពេលណា កឹម-សុខា ចេញពី ក្តារមឈូសនយោបាយ មក ដឹកនាំ យុទ្ធនាការ បោះឆ្នោត។ បើ លោក កឹម-សុខា មិនខំ រកមធ្យោបាយ ដើម្បី ធ្វើឲស្រឡះ អំពីការចោទប្រកាន់ ពីតុលាការ ហ៊ុន-សែន គាត់ នៅតែជាកុក ចំពោះ ផុច ជានិច្ច។ តែដំណោះស្រាយនេះ ត្រូវចាំបាច់ មានសេចក្តីក្លាហ៊ាន ដើម្បីប្រឈរមុខ ទល់នឹង តុលាការ ហ៊ុន-សែន មុនពេលបោះឆ្នោត ដោយយកច្បាប់សទ្ធិមនុស្ស និង តុលាអន្តរជាតិ ជាខែល។

### ករណី ព្រះមហាក្សត្រ

នៅក្នុងវប្បធម៌សន្ទនា ព្រះអង្គ គិតតែពី តែងតាំង ងារ ជា សម្តេច ដល់ សមាជិក គណបក្សប្រជាជន គ្មានហេតុផលអ្វីច្បាស់លាស់ នាំឲងារ សម្តេច វាក្លាយទៅ ជា ក្អែលរបប ធំ ខ្លិន ឆ្អាបឆ្អេះ ពាសពេញប្រទេស  នាំអោយ លោក សម-រង្ស៊ី លួចអន់ចិត្ត ថា ហេតុអ្វី ក៏ ព្រះអង្គ ភ្លេចរូបអញ។ លោក សម-រង្ស៊ី នឹងអាច ទទួល ងារ ជា សម្តេច បាន បើ គាត់ខំ រក្សា វប្បធម៌សន្ទនា ខ្សឹបៗក្នុងភោជនីយដ្ឋាន ឲបានប្រពៃ គឺ រក្សាប្រយោជន៍ឲហ៊ុន-សែន បានគង់វង់ ច្បាស់ ជា ហ៊ុន-សែន បញ្ជាទៅ ព្រះមហាក្សត្រ ជា អធិបញ្ញា ឲប្រគល់ ងារសម្តេច ដល់ សម-រង្ស៊ី។ របៀបនេះ ខ្មែរ ហៅថា ឡើងបុណ្យស័ក្ក តាមជើងខោ។ តែ បុណ្យសក្កិ បែបណា ក៏ លោក សម-រង្ស៊ី គាត់ ទទួលដែរ, ដូចជា តំណាងរាស្ត្រ ឥតចាំបាច់ បោះឆ្នោត, រដ្ឋមន្ត្រីទី១ខ្យល់, អ្នកកំដរ ហ៊ុន-សែន ។ល។ ព្រោះគាត់ជាមនុស្ស មុខក្រាស់ណាស់ ឃ្លាន កិតិយស ដើម្បី សងសឹក ដល់ វិនាដកម្ម នៃជីវិតគ្រួសារ របស់ គាត់។

### សេចក្តីសន្និដ្ឋាន

វប្បធម៌សន្ទនា ខ្សឹបៗក្នុងភោជនីយដ្ឋាន វា បញ្ឈប់បាន អាស្រ័យ ទៅលើ លោក ហ៊ុន-សែន ព្រោះ លោក ហ៊ុន-សែន ជា អ្នក ទទួលយល់ព្រម ពីការសុំ របស់ លោក សម-រង្ស៊ី។ ដូច្នេះ ពិហិការ គណបក្សសង្គ្រោះជាតិ មិនចូលបោះឆ្នោត សេចក្តីព្រាងច្បាប់ ស្តីអំពី សមាគមនិង អង្គការមិនមែន រដ្ឋាភិបាល គឺជាបញ្ហា របស់ ហ៊ុន-សែន ខាតលុយកាក់ បាវបាយ សម-រង្ស៊ី មួយពេល ហេតុនេះឯង បានជាមាន ប្រតិកម្មអវិជ្ជមាន ពីសំណាក់ក្រុម ហ៊ុន-សែន មកលើ គណបក្សសង្គ្រោះជាតិ ជាពិសេស មកលើរូប លោកសម-រង្ស៊ី និង កឹម-សុខា មួយពីបទ ឲតម្លៃផែនទីរដ្ឋាភិបាលថោកជាង ផែនទីទិញនៅផ្សារ មួយ

ដោយ ឱប សៅ សង្ហា
២០ កក្កដា ២០១៥

ទៀត ពីបទ គ្រលុក វាវី នៃវប្បធម៌សន្ទនា ឲល្អក់។ តើការនេះ វាជា សញ្ញា ចាប់ផ្ដើមបញ្ឈប់ នៃវប្បធម៌សន្ទនា ខ្សឹបៗ នៅក្នុងភោជនីយដ្ឋាន នោះឬ ? ការនេះ វា គ្មានអ្វី អាចបញ្ជាក់បាន នោះឡើយ ព្រោះ គ្មាននរណាម្នាក់ដឹង អំពី ន័យ (contenu) នៃវប្បធម៌សន្ទនា ពិតប្រាកដ នោះឡើយ ព្រោះវាមាន លក្ខណៈ ជា ការសន្ទនាខ្សឹបៗ ជា ឯកជន រវាងបុគ្គលនឹងបុគ្គល មិនមែន រវាង គណបក្សនឹងគណបក្ស នោះឡើយ។ ដូច្នេះ រឿង អវសាន នៃវប្បធម៌ នេះ ជារឿង ប្រយោជន៍ ឯកជន បើ ហ៊ុន-សែន យល់ឃើញថា គាត់ នៅអាចទាញ ចំណេញ ពី សម-រង្ស៊ី បាន គាត់ មិន បញ្ចប់ នៃវប្បធម៌សន្ទនា នេះឡើយ រីឯ សម-រង្ស៊ី វិញ គាត់មិនហ៊ាន ផ្ដើមគំនិតបញ្ចប់ វប្បធម៌សន្ទនា នេះទេ ព្រោះគាត់ខ្លាច ហ៊ុន-សែន ចោទប្រកាន់គាត់ ថាមើលងាយ ដល់ ហ៊ុន-សែន។ ដូច្នេះ វប្បធម៌សន្ទនា នេះនៅតែបន្ត ជានិច្ច ព្រោះមានយៀកណាម គេជាចិញ្ចឹម ដើម្បីប្រយោជន៍គេ។ ហ៊ុន-សែន ក្ដី សម-រង្ស៊ី ក្ដី គឺ ជា អាយ៉ងយួន តែប៉ុណ្ណោះ។

ដូច្នេះ ដំណោះស្រាយ មានតែមួយគត់ សំរាប់ខ្មែរ គឺ នាំគ្នាដើរចេញពីទ្រុងយួន ដែលជាព្រុហ្មះយាត្រា នៃកម្លាំងខ្មែរអ្នកជា ធ្វើ បដិវត្ត អហឹង្សា ប្រឆាំងនឹង អាណានិគមយៀកណាម, អំណាចផ្ដាច់ការ និង គ្រប់ជនណា ដែលបំរើប្រយោជន៍យួន នៅស្រុកខ្មែរ។ បដិវត្តអហឹង្សា គឺ ធ្វើ ពហិការ មិនចូលរួមបោះឆ្នោត ក្លែងបន្លំ និង មិនគោរពច្បាប់ណា ដែលប្រឆាំងនឹង សិទ្ធិមនុស្ស និង សេរីភាព នៃប្រជាពលរដ្ឋ។ ដំណោះស្រាយនេះ ងាយស្រួលធ្វើណាស់ព្រោះ ខ្មែរ ត្រូវការតែ ឆន្ទៈ និង សេចក្ដីក្លាហាន ជាអាវុធ អទិស្សមា តែប៉ុណ្ណោះ។ឧទាហរណ៍ នៅប្រទេស រ៉ូម៉ានី ក្នុងឆ្នាំ ១៩៨៩ គ្រាន់តែ មាន សម្រេករួមគ្នា នៃប្រជាពលរដ្ឋ វាអាច ទម្លាក់ ជនផ្ដាច់ការ Nicolae Ceaușescu បានងាយបំផុត។

ដោយ ឧប សៅ សង្ហា
២០ កក្កដា ២០១៥

ដោយ ឧប សៅ សង្ហា
២០ កក្កដា ២០១៥